# ព័ត៌មានអំពីដីកាហាមឃាត់

## មាតិកា


តើអ្វីទៅជាអំពើហិង្សាក្នុងគ្រួសារ? 1

តើអ្វីទៅជាដីកាហាមឃាត់? 1

តើខ្ញុំអាចដាក់ពាក្យសុំដីកាហាមឃាត់ដោយវិធីណា? 2

ការទៅចូលរួមក្នុងសាលាក្ដី 2

តើអ្វីនឹងកើតឡើងនៅពេលអ្នកទៅដល់សាលាក្ដី? 3

តើអ្វីនឹងកើតឡើងនៅក្នុងសាលាក្ដី? 3

តើអ្វីនឹងកើតឡើងនៅពេលដែលតុលាការចេញដីកាហាមឃាត់ឲ្យ? 4

តើអ្វីនឹងកើតឡើងបន្ទាប់ទៀតនោះ? 5

តើអ្វីនឹងកើតឡើងប្រសិនបើភាគីម្ខាងទៀតបំពានលើដីកាហាមឃាត់? 5

ចុះចំណែកដីកាពីតុលាការគ្រួសារវិញតើយ៉ាងណាដែរ? 6

តើអ្វីនឹងកើតឡើងប្រសិនបើខ្ញុំត្រូវការផ្លាស់ប្ដូរដីកាហាមឃាត់? 6

លេខទូរស័ព្ទដែលលោកអ្នកអាចសុំជំនួយ 7

ការទទួលខុសត្រូវ 8

## តើអ្វីទៅជាអំពើហិង្សាក្នុងគ្រួសារ?

អំពើហិង្សាក្នុងគ្រួសារកើតឡើងនៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងសហគមន៍យើង ហើយនិងក្នុងវប្បធម៌ទាំងអស់ផងដែរ។ អំពើហិង្សាក្នុងគ្រួសារគឺជាការរំលោភបំពាននៃអំណាចរវាងជនដែលបិតនៅក្នុងទំនាក់ទំនងជាដៃគូជិតស្និទ្ធ ឬក្រោយពីការបែកបាក់គ្នា តាមរយៈអាកប្បកិរិយារំលោភបំពានមិនសមរម្យជាច្រើនប្រភេទ។ ក្នុងនោះអាចរួមមានអំពើហិង្សាផ្លូវកាយនិងផ្លូវភេទ ការបំពានដោយប្រើសម្ដីមិនសមរម្យ ការគំរាមកំហែងផ្សេងៗនិងការធ្វើឲ្យគេក្ដៅក្រហាយ ការរំលោភបំពានតាមផ្លូវអារម្មណ៍និងតាមសង្គម ការដើរឈ្លបពីក្រោយ និងការទប់ស្កាត់មិនឲ្យជនដទៃទទួលអ្វីមួយតាមផ្នែកសេដ្ឋកិច្ច។ អាកប្បកិរិយាទាំងអស់នេះគឺជាអាកប្បកិរិយាដែលគេមិនអាចទទួលយកបាននៅក្នុងសហគមន៍យើង ហើយខ្លះគឺពិតជាអាកប្បកិរិយារំលោភច្បាប់ពិតប្រាកដ។

ប៉ូលិសក្នុងរដ្ឋអូស្ត្រាលីខាងត្បូងមានគោលដៅការពារនិងបង្កើនសុវត្ថិភាពដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។  ដីកាហាមឃាត់អាចជួយការពារអ្នកនិងក្រុមគ្រួសារអ្នក។ ក្រដាសព័ត៌មាននេះប្រាប់លោកអ្នកអំពីអ្វីដែលនឹងកើតឡើងប្រសិនបើលោកអ្នកទាក់ទងប៉ូលិសដើម្បីសុំដីកាហាមឃាត់។ យើងសង្ឃឹមថាក្រដាសព័ត៌មាននេះនឹងផ្ដល់ចម្លើយដល់សំណួរលោកអ្នក ហើយជួយអ្នកសំរេចចិត្តថាតើនឹងត្រូវធ្វើយ៉ាងណា។

## តើអ្វីទៅជាដីកាហាមឃាត់?

ដីកាហាមឃាត់ (Restraining Order) គឺជាដីកាពីតុលាការដែលហាមឃាត់មិនឲ្យជនណាម្នាក់ (ចុងចោទ) ប្រព្រឹត្តអាកប្បកិរិយាណាមួយទៅលើរូបអ្នក (ដើមចោទ) នៅក្នុងន័យដែលអាចរំខាន គំរាមកំហែង ឬរំលោភបំពានលើរូបអ្នក ឬអាចជាអំពើហិង្សា។ ភាគីម្ខាងទៀតអាចត្រូវតុលាការចេញដីកាមិនឲ្យប្រព្រឹត្តអំពើមួយចំនួនដូចជា ត្រូវគេហាមមិនឲ្យទៅផ្ទះអ្នក ឬក៏មិនត្រូវទៅសាលារៀនរបស់កូនអ្នក ត្រូវគេហាមមិនឲ្យដើរតាម ឬមើលអ្នក ឬផ្ញើសារណាមួយទៅអ្នក។ ដីកាហាមឃាត់នេះចេញឡើងសំរាប់អ្នកនិងស្ថានភាពជាក់លាក់ណាមួយរបស់អ្នកប៉ុណ្ណោះ។

វាគឺជាការរំលោភបំពានប្រសិនបើជនណាម្នាក់ធ្វើអ្វីមួយដែលដីកាហាមឃាត់បញ្ជាថាគេមិនត្រូវធ្វើដាច់ខាតនោះ។ នេះគេហៅថា "ការរំលោភបំពាន" ដីកា។ លោកអ្នកគួរតែប្រាប់ប៉ូលិសឲ្យដឹងប្រសិនបើជនដែលទទួលដីកាហាមឃាត់នោះប្រព្រឹត្តអំពើណាមួយដូចដែលបានរៀបរាប់ខាងលើ។

## តើខ្ញុំអាចដាក់ពាក្យសុំដីកាហាមឃាត់ដោយវិធីណា?

ជាធម្មតាការទៅជួបប៉ូលិសគឺជាវិធីដ៏ស្រួលបំផុតនៅក្នុងការដាក់ពាក្យសុំដីកាហាមឃាត់

ប្រសិនបើអ្នករៀបចំខ្លួនមុនទៅជួបប៉ូលិស វានឹងជួយអ្នកបាន។ យកភស្តុតាងឬព័ត៌មានណាមួយទៅជាមួយអ្នកដែលអ្នកយល់ថា អាចជួយគាំទ្រនូវសម្តីរបស់អ្នក។ ក្នុងនោះអាចមាន៖

- កំណត់ហេតុណាមួយដែលអ្នកសរសេកត់ត្រាអំពីសកម្មភាពដែលភាគីម្ខាងទៀតបានធ្វើ ក្នុងនោះរួមមានព័ត៌មានអំពីពេលវេលា និងទីកន្លែងដែលហេតុការណ៍កើតឡើង។
- រូបថតណាមួយឬភស្តុតាងនៃការខូចខាតដែលភាគីម្ខាងទៀតបានធ្វើទៅលើទ្រព្យសម្បត្តិអ្នក។
- សំណៅមួយចំនួនណាមួយអំពីដីកាតុលាការគ្រួសារដែលអនុវត្តទៅលើកូនអ្នក។

អ្នកគួរតែប្រាប់ដល់ប៉ូលិសប្រសិនបើអ្នកគិតថាភាគីម្ខាងទៀតមានកាំភ្លើង។ ពីព្រោះថាប្រសិនបើតុលាការចេញដីកាហាមឃាត់ឲ្យ តុលាការនឹងថែមទាំងចេញបញ្ជាឲ្យដកហូតយកកាំភ្លើងពីភាគីម្ខាងទៀតដែរ (ចុងចោទ) សំរាប់រយៈពេលកំណត់នៃដីកា។ សេចក្តីប្រកាសស្បថស្បែរ ដែលគេឲ្យឈ្មោះថា លិខិតថ្លែងសច្ចា នឹងត្រូវគេយកពីអ្នក។ ការធ្វើដូច្នេះនឹងបង្ហាញឲ្យឃើញអំពីស្ថានភាពរបស់អ្នក ហើយបង្កើតរួមផ្សំបានជាសំណុំរឿងសំរាប់ដាក់ពាក្យសុំដីកាហាមឃាត់។ តាមរយៈការថ្លែងសច្ចាក្នុងលិខិតថ្លែងសច្ចានេះ អ្នកប្រាប់ដល់តុលាការថា ពាក្យសម្តីទាំងអស់ដែលអ្នកបាននិយាយនៅក្នុងលិខិតថ្លែងសច្ចាគឺជាពាក្យសម្តីត្រឹមត្រូវពិតប្រាកដ។ វាគឺជាទោសមួយក្នុងការធ្វើសេចក្តីប្រកាសមិនពិតប្រាកដត្រឹមត្រូវនៅក្នុងលិខិតថ្លែងសច្ចា។ លិខិតថ្លែងសច្ចានឹងត្រូវគេបញ្ជូនទៅឲ្យផ្នែកប៉ូលិសខាងយុត្តិធម៌ព្រហ្មទណ្ឌ (Police Criminal Justice Section) ដែលរាជអាជ្ញាប៉ូលិសនឹងធ្វើការពិនិត្យមើលថា តើមានមូលហេតុគ្រប់គ្រាន់ដែរទេ ដើម្បីសុំឲ្យតុលាការចេញដីកាហាមឃាត់ដល់អ្នក។ ប្រសិនបើដូច្នេះមែន ប៉ូលិសនឹងឡើងតុលាការតាងនាមឲ្យអ្នក។ ជាធម្មតាអ្នកត្រូវតែមកស្តាប់ក្នុងតុលាការ តែទោះជាយ៉ាងដូច្នេះក្តី ប៉ូលិសទេដែលជាអ្នកឡើងនិយាយជំនួសអ្នក។

នៅក្នុងតំបន់ទីក្រុង៖
- គេនឹងប្រាប់អ្នកថាតើពេលណាអ្នកត្រូវទៅឡើងសាលាក្តីដំបូង (Magistrates Court)។

នៅក្នុងតំបន់ជនបទ៖
- ផ្នែកប៉ូលិសខាងយុត្តិធម៌ព្រហ្មទណ្ឌនឹងទាក់ទងអ្នកប្រសិនបើអ្នកត្រូវទៅឡើងសាលាក្តី។

## ការទៅចូលរួមក្នុងសាលាក្តី

អ្នកត្រូវធ្វើយ៉ាងណាឲ្យទៅដល់សាលាក្តីឲ្យទាន់ម៉ោងដែលប៉ូលិសបានប្រាប់អ្នកឲ្យទៅ។ ប្រសិនបើអ្នកទៅយឺត ឬមិនអាចទៅដល់សាលាក្តីបាន សូមទូរស័ព្ទទៅប៉ូលិស ឬសាលាក្តីឲ្យមានមុន ហើយប្រាប់អំពីមូលហេតុផ្សេងៗ។

នៅពេលអ្នកទៅដល់តុលាការ សូមសួរទៅបុគ្គលិកបំរើការនៅតុព័ត៌មានអំពីបន្ទប់សវនាការដែលអ្នកត្រូវទៅ។

## *តើអ្វីនឹងកើតឡើងនៅពេលអ្នកទៅដល់សាលាក្តី?*

ប្រសិនបើអ្នកទៅចូលរួមក្នុងសាលាក្តីនៅក្នុងតំបន់ទីក្រុង ប៉ូលិសនឹងជួបនិយាយជាមួយអ្នក។ ប្រសិនបើអ្នកទៅចូលរួមក្នុងសាលាក្តីនៅទីជនបទ រាជអាជ្ញាប៉ូលិសនឹងទៅជួបអ្នក។ ប្រសិនបើអ្នកមិនទាន់បានអាននិងធ្វើសម្បថអំពីលិខិតថ្លែងសច្ចាទេនោះ គេនឹងរៀបចំឲ្យអ្នកធ្វើនៅចំពោះមុខប៉ូលិសដែលមានការអនុញ្ញាតឲ្យធ្វើដូច្នេះ ឬនៅចំពោះមុខសារការី (Justice of the Peace)។ ត្រូវចងចាំថា វាគឺជាទោសមួយដែលអ្នកស្បថស្បែរចំពោះលិខិតថ្លែងសច្ចាដែលមានព័ត៌មានមិនត្រឹមត្រូវពិតប្រាកដ។

ដោយសារតែលិខិតថ្លែងសច្ចាអាចត្រូវគេប្រើជាភស្តុតាងនៅក្នុងតុលាការនោះ អ្នកប្រហែលជាមិនចាំបាច់ផ្តល់ភស្តុតាង (តាមសម្តី) នៅក្នុងតុលាការឡើយ។ តែទោះជាអ្នកមិនចាំបាច់ត្រូវផ្តល់ភស្តុតាងតាមសម្តីផ្ទាល់ក៏ពិតមែន តែអ្នកត្រូវតែនៅក្នុងសាលាក្តីតុលាការក្នុងអំឡុងពេលកាត់ក្តីជាដាច់ខាត។

គេនឹងប្រាប់ឲ្យអ្នកចាំនៅខាងក្រៅបន្ទប់សាលាក្តីរហូតទាល់តែចៅក្រមសាលាក្តីដំបូងត្រៀមខ្លួនរួចជាស្រេចដើម្បីស្តាប់បណ្តឹងរបស់អ្នក។ មន្ត្រីសាលាក្តីនឹងហៅអ្នកឲ្យចូលនៅពេលដល់វេលាក្តីរបស់អ្នក។

## *តើអ្វីនឹងកើតឡើងនៅក្នុងសាលាក្តី?*

**នៅក្នុងការសុំដីកាហាមឃាត់ដែលអ្នកដាក់ពាក្យសុំដើម្បីទប់ទល់នឹងជនណាមួយ ជននោះនឹងមិនស្ថិតនៅក្នុងសាលក្តីពេលដែលអ្នកដាក់ពាក្យសុំនោះឡើយ។** ប្រសិនបើជននោះទៅក្នុងសាលាក្តីដោយមូលហេតុណាមួយផ្សេងទៀត ហើយអ្នកមិនមានអារម្មណ៍ថាមានសុវត្ថិភាព សូមប្រាប់ដល់ប៉ូលិស ឬមន្ត្រីនៅក្នុងសាលាក្តីតុលាការ។

នៅពេលដែលចៅក្រមសាលាក្តីដំបូងរៀបចំខ្លួនហើយស្រេចនៅក្នុងការស្តាប់បណ្តឹងរបស់អ្នក គេនឹងប្រាប់ឲ្យអ្នកចូលមកក្នុងបន្ទប់សវនាការ ហើយអង្គុយរង់ចាំនៅជួរកៅអីខាងក្រោយបន្ទប់។ នៅពេលដែលអ្នកបានលឺគេហៅឈ្មោះជនដែលអ្នកដាក់ពាក្យសុំដីកាហាមឃាត់ទប់ទល់នោះ នោះក្តីនេះនឹងចាប់ផ្តើមឡើង។ នេះគឺជាទំរង់បែបបទនៅក្នុងតុលាការ ហើយនេះមានន័យថា ចៅក្រមសាលាក្តីដំបូងបានរៀបចំខ្លួនរួចជាស្រេចហើយដើម្បីពិនិត្យគិតគូរអំពីការដាក់ពាក្យសុំរបស់អ្នក។

**អ្នកគួរតែអង្គុយនៅកៅអីដដែល។ អ្នកមិនចាំបាច់ត្រូវធ្វើអ្វីទាំងអស់នៅក្នុងដំណាក់កាលនេះ លុះត្រាណាតែមានការស្នើពីចៅក្រមសាលាក្តីដំបូង,មន្ត្រីតុលាការ ឬប៉ូលិស។**

ប្រសិនបើចៅក្រមសាលាក្តីដំបូងត្រូវការបញ្ជាក់អ្វីមួយ គាត់អាចស្នើឲ្យអ្នកឡើងចូលទៅក្នុងកន្លែងសាក្សីអង្គុយ ដើម្បីគេសួរនាំដល់អ្នក។ តែជាធម្មតា គេតែងសួរនាំអ្នកនៅពេលដែលអ្នកអង្គុយនៅនៅជួរកៅអីខាងក្រោយនៅក្នុងសាលាក្តី ហើយអ្នកអាចឆ្លើយសំណួរពីទីនោះក៏បានដែរ។ ប៉ូលិសអាចនឹងសួរសំណួរណាមួយដល់អ្នកប្រសិនបើពួកគេត្រូវការព័ត៌មានបន្ថែមអំពីរឿងណាមួយ។ សូមស្តាប់សំណួរឲ្យបានច្បាស់លាស់ ហើយឆ្លើយសំណួរឲ្យបានត្រឹមត្រូវ។

នៅពេលដែលចៅក្រមសាលាក្តីដំបូង (Magistrate) បានធ្វើការសំរេចកាត់ក្តីហើយ គាត់នឹងប្រាប់អ្នកថា តុលាការនឹងផ្តល់ដីកាហាមឃាត់ដល់អ្នកឬយ៉ាងណា។

សូមស្តាប់នូវអ្វីដែលចៅក្រមសាលាក្តីដំបូងមានប្រសាសន៍ទៅកាន់អ្នក ក្រោយពីគាត់បានអានសំណុំពាក្យរបស់អ្នករួចហើយ។ ប្រសិនបើអ្នកស្តាប់កន្លែងណាមិនទាន់ អ្នកអាចសួរដល់ប៉ូលិសក្រោយពីសវនាការ ហើយប៉ូលិសនឹងពន្យល់នូវអ្វីដែលបានកើតឡើង ហើយឆ្លើយទៅនឹងសំណួរទាំងឡាយណាដែលអ្នកមានចម្ងល់។

## *តើអ្វីនឹងកើតឡើងនៅពេលដែលតុលាការចេញដីកាហាមឃាត់ឲ្យ?*

តុលាការនឹងចេញដីកាឲ្យភ្លាមនៅក្នុងថ្ងៃដដែល តែទោះជាយ៉ាងដូច្នេះក្តី វាមានសារសំខាន់ណាស់នៅក្នុងការដឹងថា ដីកានេះ**មិនមានប្រសិទ្ធភាពឡើយលុះត្រាណាតែប៉ូលិសបានប្រគល់សំណៅដីកានេះដល់អ្នកដោយផ្ទាល់** (កិច្ចបំរើដីកា) **ទៅដល់ភាគីម្ខាងទៀត** (ចុងចោទ)។ ប្រសើរបើអាចធ្វើទៅបានសូមកុំប្រាប់ដល់ភាគីម្ខាងទៀតថា ប៉ូលិសនឹងប្រគល់ដីកាហាមឃាត់ដល់គេ ដោយហេតុថា ការធ្វើដូច្នេះនាំឲ្យប៉ូលិសមានការលំបាកជាងមុននៅក្នុងការប្រគល់ដីកានេះ។

**ប៉ូលិសនឹងប្រាប់ដល់អ្នកថា តើប៉ូលិសបានប្រគល់ដីកានេះហើយឬនៅ** តែទោះជាយ៉ាងដូច្នេះក្តីប្រសិនបើអ្នកមានការបារម្ភ លោកអ្នកអាចសួរទៅឯស្ថានីយប៉ូលិសនៅជិតផ្ទះរបស់អ្នកគ្រប់ពេលវេលា។

អ្នកនឹងទទួលសំណៅដីកានេះ**ចំនួន៣ច្បាប់** តាមរយៈការផ្ញើតាមប៉ុស្តិ៍ ឬពីប៉ូលិស២ឬ៣ថ្ងៃក្រោយពីអ្នកបានទៅចូលរួមនៅក្នុងតុលាការ។ វាជាការប្រសើរណាស់ដែលអ្នកទុកសំណៅដីកានេះមួយច្បាប់នៅកន្លែងណាដែលមានសុវត្ថិភាព ហើយមួយច្បាប់ទៀតនៅនឹងខ្លួនអ្នក (ឧទាហរណ៍នៅក្នុងកាបូប ឬក្នុងឡានជាដើម) ហើយប្រគល់សំណៅទីបីដល់ជនណាម្នាក់ដែលអាចត្រូវការដីកានេះ (ឧទាហរណ៍សាលារៀនដែលកូនអ្នកទៅរៀន)។

សូមអានសំណៅដីកានេះឲ្យបានត្រឹមត្រូវ ដើម្បីឲ្យអ្នកដឹងថាអ្វីដែលភាគីម្ខាងទៀត (ចុងចោទ) អាចនិងមិនអាចធ្វើបាន (លក្ខខណ្ឌ)។ ការធ្វើបែបនេះអ្នកនឹងដឹងថា ប្រសិនបើភាគីម្ខាងទៀតធ្វើអ្វីមួយដែលបំពានទៅលើលក្ខខណ្ឌដែលមានចែងក្នុងដីកា ហើយក្នុងករណីនោះអ្នកអាចទាក់ទងទៅប៉ូលិសបាន។

ជាធម្មតាតុលាការចេញដីកាឲ្យដោយដាក់កំណត់ពេលវេលា ឧទាហរណ៍ សំរាប់ពេល១ ឬ២ឆ្នាំ។ ប្រសិនបើគេមិនបានកំណត់រយៈពេលនៅក្នុងដីកាទេនោះ នេះមានន័យថា ដីកានេះនឹងមានប្រសិទ្ធភាពបន្តរហូតដោយមិនមានកំណត់ពេលជាក់លាក់។

## *តើអ្វីនឹងកើតឡើងបន្ទាប់ទៀតនោះ?*

ដីកាហាមឃាត់ថែមទាំងមានចែងនូវកាលបរិច្ឆេទសំរាប់ភាគីម្ខាងទៀតដែលត្រូវទៅឡើងតុលាការប្រសិន**បើភាគីនោះមិនយល់ស្របទៅនឹងលក្ខខណ្ឌផ្សេងៗ**ដែលបានកំណត់ឡើងនៅក្នុងដីកាហាមឃាត់នេះ។ ប៉ូលិសនឹងព្យាយាមសម្របសម្រួលការមិនយល់ស្របណាមួយ បន្ទាប់មកនឹងប្រាប់អ្នកឲ្យដឹងប្រសិនបើមានអ្វីមួយត្រូវគេផ្លាស់ប្តូរនៅក្នុងដីកានេះ។ **អ្នកមិនចាំបាច់ទៅឡើងតុលាការនៅក្នុងថ្ងៃដែលគេចែងនៅក្នុងដីកាឡើយ**។ ប្រសិនបើភាគីម្ខាងទៀតនៅតែមិនយល់ស្របទៅនឹងដីកានេះក្រោយពីបានស្តាប់សវនាការរួចហើយ នោះនឹងមានករណីឡើងតុលាការម្តងទៀតនៅពេលក្រោយ។

ប៉ូលិសនឹងប្រាប់អ្នកប្រសិនបើអ្នកត្រូវទៅឡើងតុលាការ ហើយប្រសិនបើដូច្នេះ តើនៅពេលណាហើយកន្លែងណាដែលអ្នកត្រូវទៅ។ **ប្រសិនបើអ្នកត្រូវទៅឡើងតុលាការនៅក្នុងដំណាក់កាលនេះ អ្នកនឹងត្រូវផ្តល់ភស្តុតាងនៅក្នុងកន្លែងសាក្សីអង្គុយ**។ ភាគីម្ខាងទៀត (ចុងចោទ) នឹងចូលរួមស្តាប់សវនាការក្នុងតុលាការផងដែរ ដូច្នេះប្រសិនបើអ្នកមិនមានអារម្មណ៍ថាមានសុវត្ថិភាពទេនោះ សូមប្រាប់ទៅប៉ូលិស ហើយគេនឹងព្យាយាមរៀបចំវិធីណាមួយដើម្បីធ្វើឲ្យអ្នកមានអារម្មណ៍មានសុវត្ថិភាព។

វាពិតជាមានសារសំខាន់ណាស់នៅក្នុងការចងចាំថា ដីកាហាមឃាត់នឹងមានប្រសិទ្ធភាពរហូតទាល់តែទីចុងបញ្ចប់នៃសវនាការបែបនេះ។ ពេលនោះតុលាការនឹងអាចសំរេចបញ្ជាក់លើដីកាហាមឃាត់នេះ។ ប្រសិនបើដូច្នេះមែនដីកានេះនឹងបន្តផ្តល់ការការពារដល់អ្នករហូតទាល់តែដីកានេះផុតកំណត់ ឬត្រូវតុលាការផ្លាស់ប្តូរ។

## *តើអ្វីនឹងកើតឡើងប្រសិនបើភាគីម្ខាងទៀតបំពានលើដីកាហាមឃាត់?*

ប្រសិនបើចុងចោទបំពានលើលក្ខខណ្ឌណាមួយនៅក្នុងដីកានេះ គេហៅថា ការបំពានដីកា។ នេះគឺជាបទព្រហ្មទណ្ឌ ហើយចុងចោទអាចត្រូវគេប្តឹងឡើងតុលាការ។

អ្នកគួរតែមានការប្រុងប្រយ័ត្នហើយមិនត្រូវធ្វើអ្វីមួយដែលបំពានលើដីកានេះឡើយ ឬក៏មិនត្រូវធ្វើឲ្យភាគីម្ខាងទៀតបំពានដីកានេះដែរ។ ឧទាហរណ៍ ប្រសិនបើគេហាមមិនឲ្យភាគីម្ខាងទៀតទៅទាក់ទងអ្នក ពេលនោះអ្នកមិនត្រូវទៅទាក់ទង ឬទៅជួបភាគីម្ខាងទៀត ឬទូរស័ព្ទទៅគេឡើយ។ បើមិនដូច្នេះទេ អ្នកអាចរំលោភបំពានច្បាប់ផងដែរ ហើយអាចត្រូវគេប្តឹងឡើងតុលាការផង។

ប្រសិនបើមានការរំលោភបំពានណាមួយលើដីកាហាមឃាត់ធ្វើឡើងដោយចុងចោទ នៅក្នុងពេលមានវត្តមានរបស់អ្នកនោះ ឬអ្នកមានអារម្មណ៍ថាកំពុងមានគ្រោះថ្នាក់ អ្នកគួរតែទូរស័ព្ទទៅលេខ 131 444 (ឬទៅលេខ 000 នៅក្នុងករណីគ្រាអាសន្ន) ហើយពេលនោះគេនឹងបញ្ជូនអ្នកយាមល្បាតទៅជួយអ្នក។

ប្រសិនបើអ្នកគិតថា មានការរំលោភបំពានណាមួយលើដីកាហាមឃាត់ តែអ្នកមិនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ភ្លាមៗ (ឧទាហរណ៍ នៅពេលដែលចុងចោទបានទៅលេងកូនអ្នកនៅសាលារៀន ដែលផ្ទុយទៅនឹងលក្ខខណ្ឌណាមួយនៅក្នុងដីកា) **អ្នកគួរតែរាយការណ៍អំពីហេតុការណ៍នេះទៅប្រាប់ដល់ស្ថានីយប៉ូលិសក្នុងតំបន់អ្នក** ដើម្បីអាចឲ្យប៉ូលិសស៊ើបអង្កេតអំពីរឿងនេះ។

ត្រូវចងចាំថា ដីកាហាមឃាត់នេះអាចមានប្រសិទ្ធភាពទៅបានលុះត្រាណាតែអ្នកអនុញ្ញាតឲ្យវាមានប្រសិទ្ធភាពតែប៉ុណ្ណោះ។ ត្រូវរាយការណ៍អំពីរាល់ការរំលោភបំពាន់ទាំងឡាយឲ្យបានភ្លាមៗ។

## *ចុះចំណែកដីកាពីតុលាការគ្រួសារវិញតើយ៉ាងណាដែរ?*

ប្រសិនបើមានការពាក់ព័ន្ធជាមួយកូន **វាអាចចាំបាច់ដែលអ្នកត្រូវសុំឱវាទផ្លូវច្បាប់** ដើម្បីជួយអ្នកសំរេចចិត្តថាអ្នកគួរតែដាក់ពាក្យសុំទៅតុលាការគ្រួសារដើម្បីសុំដីកាពីតុលាការគ្រួសារវិញឬយ៉ាងណា។ វាមានសារសំខាន់ណាស់ក្នុងការចងចាំថាលក្ខខណ្ឌនៅក្នុងដីកាពីតុលាការគ្រួសារអាចមាន**អំណាចលប់ចោលនូវលក្ខខណ្ឌចាស់ណាមួយដែលមានចែងនៅក្នុងដីកាហាមឃាត់**។ ប៉ូលិសអាចពន្យល់អំពីរឿងនេះដល់អ្នក។

## *តើអ្វីនឹងកើតឡើងប្រសិនបើខ្ញុំត្រូវការផ្លាស់ប្តូរដីកាហាមឃាត់?*

ប្រសិនបើកាលៈទេសៈរបស់អ្នកមានការផ្លាស់ប្តូរ ហើយអ្នកមានបំណងចង់ប្តូរលក្ខខណ្ឌណាមួយនៅក្នុងដីកាហាមឃាត់ ឬលប់ចោលដីកាហាមឃាត់នេះ នោះអ្នកត្រូវទាក់ទងទៅខាងផ្នែកស៊ើបអង្កេតគ្រួសារនិងកូន (Child Family Investigation Unit) ឬស្ថានីយប៉ូលិសក្នុងតំបន់អ្នក ហើយប្រាប់ប៉ូលិសអំពីមូលហេតុដែលអ្នកចង់ឲ្យមានការផ្លាស់ប្តូរឬលប់ចោលដីកាហាមឃាត់នេះ។

ការឡើងតុលាការម្តងទៀតនឹងត្រូវរៀបចំឡើងសំរាប់ការផ្លាស់ប្តូរឬការលប់ចោលដីកាណាមួយ។ វាមានសារសំខាន់ណាស់សំរាប់អ្នកក្នុងការយល់ថាមានតែតុលាការប៉ុណ្ណោះទេដែលអាចផ្លាស់ប្តូរ ឬលប់ចោលដីកាណាមួយបាន។ ដីកាដែលចេញឡើងឲ្យអ្នកមិនអាចត្រូវគេផ្លាស់ប្តូរបានដោយគ្រាន់តែមានការយល់ព្រមពីអ្នក និងភាគីម្ខាងទៀតដែលគេយល់ព្រមប្តូរនោះទេ។

គេនឹងផ្តល់ឱវាទប្រាប់អ្នកនិងភាគីម្ខាងទៀតអំពីពេលវេលានិងកាលបរិច្ឆេទនៃការឡើងសវនាការ។ អ្នកត្រូវតែទៅចូលរួមនៅក្នុងសាលាក្តីអំពីរឿងនេះ។ ជាធម្មតាភាគីម្ខាងទៀតក៏ត្រូវតែទៅចូលរួមក្នុងសាលាក្តីនេះដែរ។

ប៉ូលិសនិងតុលាការទទួលស្គាល់ថា ពេលខ្លះស្ថានភាពមានការផ្លាស់ប្តូរក្នុងន័យល្អ ហើយដីកាក៏ត្រូវតែមានការផ្លាស់ប្តូរផងដែរ។ តែទោះជាយ៉ាងដូច្នេះក្តី ប៉ូលិសក៏ត្រូវតែមានការយល់ឃើញគ្រប់គ្រាន់ដែរថា អ្នកនៅតែមានសុវត្ថិភាពដដែល ហើយអ្នកក៏មិនត្រូវគេដាក់សម្ពាធបង្ខំឲ្យធ្វើការផ្លាស់ប្តូរ ដែលអាចធ្វើឲ្យអ្នក និងគ្រួសារអ្នកប្រឈមមុខនឹងគ្រោះថ្នាក់កាន់តែខ្លាំងឡើង។

ពេលខ្លះប៉ូលិសនឹងមិនយល់ព្រមឡើងតុលាការដើម្បីអ្នកនៅក្នុងការដាក់ពាក្យផ្លាស់ប្តូរឬលុបចោលវិញនូវដីកាហាមឃាត់ឡើយ ប្រសិនបើប៉ូលិសជឿជាក់ថា សកម្មភាពបែបនេះនឹងបង្កឲ្យមានគ្រោះថ្នាក់កាន់តែខ្លាំងឡើង ដែលធ្វើឲ្យអ្នកនិងគ្រួសារអ្នកត្រូវទទួលរងទុក្ខថែមទៀតដោយសារអំពើហិង្សាក្នុងគ្រួសារ។

## *លេខទូរស័ព្ទដែលលោកអ្នកអាចសុំជំនួយ*

| | | | |
|---|---|---|---|
| ក្នុងគ្រាមានអាសន្នសូមទូរស័ព្ទទៅលេខ | | | 000 |
| ត្រូវការជំនួយប៉ូលិស/ចង់ឲ្យប៉ូលិសទៅជួបសូមទូរស័ព្ទទៅលេខ | | | 131 444 |
| ផ្នែកប៉ូលិសស៊ើបអង្កេតលើគ្រួសារនិងកូន | | | |
| អាដឺឡែដ (Adelaide) | 8463 7090 | A/H | 8346 7007 |
| អេលីហ្សាបែត (Elizabeth) | 8207 9353 | A/H | 8207 9442 |
| ហូលដិនហ៊ីល (Holden Hill) | 8207 6034 | A/H | 8207 6000 |
| ផតអាដឺឡែដ (Port Adelaide) | 8207 6413 | A/H | 8207 6444 |
| តំបន់ឆ្នេរខាងត្បូង (South Coast) | 8392 9172 | A/H | 8392 9000 |
| តំបន់ស្ទើត (Sturt) | 8207 4801 | A/H | 8207 4700 |

នៅតាមទីជនបទសូមទាក់ទងទៅស្ថានីយប៉ូលិសក្នុងតំបន់របស់អ្នក។

ប្រសិនបើអ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារដោយសារអ្នកមានប្រវត្តិមិនមែនជាជនជាតិដែលនិយាយភាសាអង់គ្លេស ហើយត្រូវការជំនួយ និងការគាំទ្រដើម្បីឲ្យយល់អំពីដំណើរការសុំដីកាហាមឃាត់នេះ សូមទាក់ទងទៅ **សេវាស្នាក់នៅនិងការគាំទ្ររបស់ស្ត្រីអន្តោប្រវេសន៍ (Migrant Women's Support and Accommodation Service)** តាមទូរស័ព្ទលេខ **8346 9417** ។

បញ្ជីរាយឈ្មោះទីភ្នាក់ងារ ដែលអាចផ្តល់ជាជំនួយនិងការគាំទ្រដល់អ្នកថែមទៀតក្នុងនាមអ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អ្នកអាចយកបានពីស្ថានីយប៉ូលិសក្នុងតំបន់របស់អ្នក។

**ការទទួលខុសត្រូវ៖** ការបោះពុម្ពផ្សាយនេះ ត្រូវបានរៀបចំឡើងដោយកិច្ចផ្តួចផ្តើមសេវាសាធារណៈរបស់ប៉ូលិសអូស្ត្រាលីខាងត្បូង។ ការបោះពុម្ពនេះផ្តល់នូវព័ត៌មានទូទៅក្នុងន័យជាសេចក្តីណែនាំដែលអាចអនុវត្តបានដើម្បីជួយលើកតំកើងសុវត្ថិភាព និងកាត់បន្ថយគ្រោះថ្នាក់នៃឧក្រិដ្ឋកម្ម។

នៅក្នុងខណៈពេលដែលមានការយកចិត្តទុកដាក់ហ្មត់ចត់នៅក្នុងការរៀបចំការបោះពុម្ពនេះ គេមិនមានការធានា ឬតំណាង តាមរយៈការបញ្ចេញឬការបញ្ជាក់ដែលបានធ្វើឡើងពាក់ព័ន្ធនឹងភាពត្រឹមត្រូវ បច្ចុប្បន្នភាព ឬភាពស៊ីសង្វាក់ទៅតាមគោលបំណងនៃព័ត៌មានដែលមាននេះ ឬក៏ឱវាទដែលផ្តល់ជូននៅក្នុងការបោះពុម្ពផ្សាយនេះឡើយ។

មិនមានការធានា ឬតំណាង តាមរយៈការបញ្ចេញឬការបញ្ជាក់ ត្រូវគេធ្វើឡើងទាក់ទងនឹងលទ្ធផលផ្សេងៗនៃការពឹងអាស្រ័យទៅលើព័ត៌មានដែលមាន ឬឱវាទដែលផ្តល់ជូននៅក្នុងការបោះពុម្ពនេះឡើយ។ គេមិនមានការទទួលខុសត្រូវចំពោះកំហុសផ្សេងៗ ឬការបាត់បង់ព័ត៌មានដែលមានចែងនៅក្នុងការបោះពុម្ពនេះឡើយ ឬចំពោះការបាត់បង់ផ្សេងៗដែលទទួលរងទុក្ខដោយជនណាម្នាក់ដោយសារតែពឹងអាស្រ័យទៅលើព័ត៌មានដែលមានចែងនៅក្នុងការបោះពុម្ពនេះឡើយ។

គេមានការជំរុញលើកទឹកចិត្តដល់អ្នកអានឲ្យស្វែងរកឱវាទផ្លូវច្បាប់ និងឱវាទពីអ្នកមានអាជីពដែលមានការពាក់ព័ន្ធទាក់ទងនឹងកាលៈទេសៈរបស់បុគ្គលម្នាក់ៗ។

© 2005 រដ្ឋអូស្ត្រាលីខាងត្បូង
ការបោះពុម្ពផ្សាយនេះត្រូវគេរក្សាសិទ្ធិគ្រប់យ៉ាង ហើយជាកម្មសិទ្ធិរបស់រដ្ឋាភិបាលអូស្ត្រាលីខាងត្បូង។ ក្រៅពីការប្រើប្រាស់ដែលមានការអនុញ្ញាតដូចដែលបានចែងនៅក្នុងច្បាប់រក្សាសិទ្ធិឆ្នាំ ១៩៦៨ នោះ មិនមានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវគេយកទៅផលិតសាឡើងវិញដោយដំណើរការណាមួយ ដោយមិនមានការអនុញ្ញាតជាក់លាក់តាមការសរសេរលាយលក្ខណ៍អក្សរពីម្ចាស់រក្សាសិទ្ធិឡើយ។ រាល់ការសាកសួរទាំងឡាយគួរតែសរសេរទៅកាន់ប៉ូលិសអូស្ត្រាលីខាងត្បូង ប្រអប់សំបុត្រលេខ Box 1539, GPO, ADELAIDE, South Australia 5001 ។
(This publication is the copyright of the Crown in right of the State of South Australia. Apart from any use permitted by the Copyright Act 1968 (Cth), no part of this publication may be reproduced by any process without the specific written permission of the copyright owner. Inquiries should be addressed to South Australia Police, Box 1539, GPO, ADELAIDE, South Australia 5001.)

សូមប្រគល់បដិកាគុណទៅខាងផ្នែកសិក្សាយុត្តិធម៌ Justice Studies TAFE SA Adelaide South ចំពោះការចូលរួមចំណែកនៅក្នុងការតាក់តែង និងការបោះពុម្ពកូនសៀវភៅព័ត៌មាននេះ។

ចូលរួមផលិតរួមគ្នាដោយ ផ្នែកកាត់បន្ថយឧក្រិដ្ឋកម្ម (Crime Reduction Section), ប៉ូលិសរដ្ឋអូស្ត្រាលីខាងត្បូង (South Australia Police), និងផ្នែកសម្របសម្រួលជនរងគ្រោះនៃឧក្រិដ្ឋកម្ម (Victims of Crime Co-ordinator), ផ្នែកយុទ្ធសាស្ត្រយុត្តិធម៌ និងគោលនយោបាយ និងច្បាប់ (Justice Strategy Unit and Policy & Legislation Section), ក្រសួងអគ្គមេធាវីរដ្ឋអូស្ត្រាលីខាងត្បូង (Attorney-General's Department)។